# ទស្សនៈរបស់ខ្ញុំចំពោះប្រវត្តិសាស្ត្រខ្មែរក្រហមនិងការទប់ស្កាត់ការកាប់សម្លាប់

ខ្ញុំបាទឈ្មោះ ម៉ូហាំម៉ាត់ តហៀត អាប៊ូបាកើរ អាយុ២៨ឆ្នាំ រស់នៅឃុំត្រពាំងសង្កែ ស្រុកកំពត ខេត្តកំពត ។ ទោះបីខ្ញុំកើតមិនទាន់របបនោះទេ ក៏ប៉ុន្តែចំពោះព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងរបបនោះគឺខ្ញុំបានដឹងច្រើនតាមរយៈឪពុកម្តាយរបស់ខ្ញុំនិងអ្នកជិតខាងដែលបាននិយាយប្រាប់ខ្ញុំ ។

ពីដំបូង ខ្ញុំមិនជឿថាមានរបបខ្មែរក្រហមទេ ។ ពេលដែលឪពុកម្តាយនិងចាស់ៗនៅជិតខាងនិយាយប្រាប់ខ្ញុំពីរឿងនេះ ខ្ញុំបែរជាគិតថាវាជារឿងព្រេងនិទានរបស់ខ្មែរ ព្រោះបើយើងស្តាប់ទៅវាគឺជារឿងមួយដែលមិនគួរឲ្យជឿទាល់តែសោះ ។ ឧទាហរណ៍ខ្មែរក្រហមប្រើក្មេងៗដើម្បីបញ្ឈ្លាមនុស្សចាស់ជាងខ្លួនឲ្យធ្វើការងារ ។ ខ្មែរក្រហមយកមនុស្សទៅសម្លាប់ដោយវាយនឹងគល់ឫស្សី និងប្រើឧបករណ៍ផ្សេងៗទៀតដូចជា ពូថៅ ចប ជាដើម ហើយខ្មែរក្រហមសម្លាប់អ្នកចេះដឹងចោលទុកតែមនុស្សល្ងង់ ។ ខ្មែរក្រហមប្រើមនុស្សដូចជាសត្វធាតុដោយឲ្យមនុស្សធ្វើការលើសកម្លាំងពលកម្មដែលប្រជាជនមាន ប៉ុន្តែផ្តល់របបអាហារតិចតួចប៉ុណ្ណោះ ។ សូម្បីតែផលដំណាំដែលបានមកពីកម្លាំងពលកម្មរបស់ខ្លួន ក៏ខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនហូបដែរ ហើយមិនដឹងថា ខ្មែរក្រហមនាំផលដំណាំទាំងនោះទៅណាឡើយ ។

សូម្បីតែការនិយាយស្តីក៏ត្រូវខ្មែរក្រហមកម្រិតឲ្យនិយាយ ។ មនុស្សគ្មានសេរីភាពក្នុងការនិយាយស្តីឡើយ ។ ពេលយប់ឡើង ឈ្លបខ្មែរក្រហមពួននៅក្រោមផ្ទះលួចស្តាប់ប្រជាជននិយាយគ្នា ។ ប្រសិនបើការណ៍ប្រឆាំងនឹងអង្គការ នឹងត្រូវនាំយកទៅសម្លាប់នៅព្រឹកបន្ទាប់ ។ រឿងរ៉ាវគួរឲ្យរន្ធត់ទាំងនេះបានកើតឡើងតាំងពី២៧ឆ្នាំមុនប៉ុន្តែវាហាក់ដូចជានៅថ្មីៗសម្រាប់អ្នកដែលបានឆ្លងកាត់របបនោះ ។

នៅពេលខ្ញុំធំដឹងក្តីឡើង ខ្ញុំក៏ចាប់ផ្តើមសួរខ្លួនឯងថា តើរឿងរ៉ាវដែលឪពុកម្តាយនិងចាស់ៗនិយាយប្រាប់ខ្ញុំគឺជារឿងពិតឬអត់? ដូច្នេះដើម្បីដោះស្រាយចម្ងល់ផ្ទាល់ខ្លួន ខ្ញុំក៏ខិតខំរកមើលឯកសារផ្សេងៗដែលនិយាយពីរបបខ្មែរក្រហម ដូចជាការធ្វើទារុណកម្មទៅលើប្រជាជននៅក្នុងរបបនោះ ។ គួររំឭកដែរថា មានពេលមួយនោះខ្ញុំបានទៅលេងខេត្តកំពង់ឆ្នាំងហើយខ្ញុំបានស្នាក់នៅក្នុងសូរ៉ាវ (កន្លែងថ្វាយបង្គំដែលមានទំហំតូចជាវិហារអ៊ីស្លាម) មួយដែលនៅលើសូរ៉ាវនោះមានសៀវភៅជាច្រើនទាក់ទងនឹងសាសនាអ៊ីស្លាម ។ ក៏ប៉ុន្តែក្នុងចំណោមសៀវភៅទាំងនោះ មានសៀវភៅ២-៣ក្បាលដែលនិយាយពីរបបខ្មែរក្រហមនិងជនជាតិចាមដែលរងគ្រោះនៅក្នុងរបបនោះ (ខ្ញុំមិនចាំថាសៀវភៅនោះមានប្រភពដើមមកពីណាឬបោះពុម្ពដោយអង្គការណាទេ) ។ ខ្ញុំសប្បាយចិត្តណាស់ព្រោះចំនឹងអ្វីដែលខ្ញុំកំពុងតែ

ឆ្នល់ ។ ខ្ញុំក៏យកសៀវភៅទាំងនោះមកអាន ។ ពេលដែលខ្ញុំអានបានពទំព័រ ខ្ញុំមានអារម្មណ៍ថា ពួកខ្មែរក្រហម ដែលមានមេដឹកនាំប៉ុលពត គឺជាមនុស្សសាហាវបំផុត ។ ពួកគេបានធ្វើបាបជនជាតិចាម ដោយបង្ខំឲ្យហូបសាច់ជ្រូក មិនឲ្យសំពះយ៉ាង ហើយបង្ខំឲ្យធ្វើការងារលើសកម្រិត ។ រឿងរ៉ាវនោះ មានទាំងបញ្ជាក់ពីទីកន្លែងកើតហេតុច្បាស់លាស់ទៀតផង ។ ដូច្នេះខ្ញុំគិតថាអ្វីៗដែលចាស់ៗនិយាយ ប្រាប់ខ្ញុំកាលពីមុនសុទ្ធតែជារឿងពិតទាំងអស់ ។ ក្រោយមកទៀត ខ្ញុំរឹតតែបានច្បាស់លាស់ទៀត នៅពេលដែលខ្ញុំទៅទស្សនាគុកទួលស្លែង ហើយអ្វីដែលធ្វើឲ្យខ្ញុំជឿកាន់តែខ្លាំងនោះគឺនៅពេលខ្ញុំបាន ឃើញសម្ភៀកបំពាក់ ឧបករណ៍ធ្វើទារុណកម្មសព្វបែបយ៉ាងដែលពួកខ្មែរក្រហមប្រើដើម្បីធ្វើទារុណកម្ម និងឈ្លេចយកចម្លើយពីអ្នកទោស និងរូបថតអ្នកទោសជាច្រើនដែលខ្មែរក្រហមបានថតមុននឹងបញ្ជូន ចូលតាមបន្ទប់ ។ បន្ទាប់មកទៀត ខ្ញុំបានធ្វើដំណើរទៅមើលវាលពិឃាតជើង ជាកន្លែងមួយដែលខ្មែរ ក្រហមបញ្ជូនអ្នកទោសចេញពីគុកទួលស្លែងមកសម្លាប់នៅទីនេះ ។ ពួកខ្មែរក្រហមសម្លាប់មនុស្ស យ៉ាងសាហាវបំផុត ។ នៅទីនោះមានរណ្ដៅសាកសពរួមធំៗជាច្រើន ហើយលលាដ៍ក្បាលរបស់ ជនរងគ្រោះត្រូវបានដាក់គរលើគ្នានៅក្នុងបូជនីយដ្ឋានមួយដែលទើបតែសាងសង់ក្រោយរបបខ្មែរ ក្រហមដួលរលំ ។ ខ្ញុំមានអារម្មណ៍អាណិតអាសូរជនរងគ្រោះដែលជាជនស្លូតត្រង់ ប៉ុន្តែខ្ញុំខឹងខ្មែរក្រហម យ៉ាងខ្លាំងដោយបានធ្វើឲ្យប្រជាជនកម្ពុជាស្លាប់ដោយអយុត្តិធម៌ ។ របបខ្មែរក្រហមគឺជារបបខ្មៅងងឹត ហើយដែលមនុស្សមិនចង់ជួបប្រទះមួយជីវិត ។

ក្នុងនាមខ្ញុំជាយុវជនម្នាក់ ខ្ញុំយល់ថារបបខ្មែរក្រហមគឺជារបបមួយដែលមាននយោបាយប្លែកពី គេ ។ បើយើងមើលប្រទេសមួយចំនួនផ្សេងទៀតនៅក្នុងពិភពលោកដែលគេប្រកាន់យករបបកុម្មុយនិស្ត គឺមានការរីកចម្រើនជាងយើងច្រើន ។ ចំណែកប្រទេសកម្ពុជាគ្មានការរីកចម្រើនអ្វីទាំងអស់ ។ ខ្មែរ ក្រហមលុបបំបាត់ទីផ្សារ សាលារៀន វត្តអារាម វិហារអ៊ីស្លាម និងវិស័យផ្សេងៗជាច្រើនទៀត ។ ទោះបីជាខ្ញុំកើតមិនទាន់របបនោះមែន ក៏ប៉ុន្តែទង្វើដែលពួកឃាតករមុខខ្មៅ ដៃប្រលាក់ឈាម ប្រជាជន កម្ពុជាគឺស្ថិតជាប់នៅក្នុងបេះដូងខ្ញុំជានិច្ច ។

ខ្ញុំមិនចង់ឲ្យរបបនេះកើតឡើងលើទឹកដីខ្មែរយើងទៀតឡើយ ព្រោះវាគ្មានផលចំណេញអ្វីទាំង អស់ ក្រៅពីធ្វើឲ្យប្រទេសជាតិខ្ទេចខ្ទីដែលហ៊ានសម្លាប់ខ្មែរគ្នាឯងនិងជនជាតិភាគតិចដទៃទៀត ព្រមទាំងធ្វើឲ្យប្រទេសជាតិចុះអន់ខ្សោយនិងមានកេរ្តិ៍អសោធ ។ ដើម្បីកុំឲ្យរបបនេះកើតឡើងសាជាថ្មី យុវវ័យនិងក្មេងៗជំនាន់ក្រោយត្រូវខិតខំរៀនសូត្រនិងត្រូវចេះបែងចែកល្អនិងអាក្រក់ ។ យើងត្រូវ តែខិតខំធ្វើអ្វីដែលសង្គមត្រូវការ ហើយមិនត្រូវយកគំរូពីពួកឃាតករមុខខ្មៅដៃប្រឡាក់ឈាមនោះ ឡើយ ។ យើងត្រូវតែចេះប្រៀបធៀបរវាងរបបខ្មែរក្រហមនិងសង្គមយើងបច្ចុប្បន្នដើម្បីចៀសវាង

*នូវកំហុសដដែល ។*

*យើងត្រូវដឹងពីស្វែងយល់ពីការលំបាកនិងទុក្ខវេទនារបស់ឪពុកម្ដាយយើងដែលបានទទួលរងក្នុងរបប នោះ ហើយយើងគួរសិក្សាពីការប៉ះទង្គិចរបស់របបខ្មែរក្រហមមកលើប្រជាជនកម្ពុជាសព្វថ្ងៃ ។*

*ខ្ញុំសូមសំណូមពរដល់ស្ថាប័ននិងអង្គការផ្សេងៗ មេត្តាជួយបើវគ្គសិក្ខាសាលាដែលស្ដីអំពីខ្មែរក្រហមឲ្យបានច្រើនដល់យុវវ័យនិងបង្កើតកម្មវិធីទស្សនកិច្ចសិក្សាដល់យុវវ័យ ដើម្បីមានលទ្ធភាពទៅមើលទីតាំងប្រល័យពូជសាសន៍ ដូចជា គុកទួលស្លែងនិងវាលពិឃាតជើងឯក និងកន្លែងផ្សេងៗទៀត ។ តាមរយៈកិច្ចការខាងលើនេះមានផលប្រយោជន៍ច្រើនសម្រាប់យុវជន ព្រោះពួកគេអាចឃើញផ្ទាល់ភ្នែកនិងជឿជាក់ថារបបខ្មែរក្រហមពិតជាបានកើតមានឡើងតាំងពី៣០ឆ្នាំមុន ។*

*ខ្ញុំសំណូមពរឲ្យរាជរដ្ឋាភិបាលបញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមនេះទៅក្នុងកម្មវិធីសិក្សាសាលារដ្ឋចាប់ពីថ្នាក់ទី៧ដល់ថ្នាក់ទី៩ ព្រោះនៅក្នុងកម្រិតនេះ សិស្សានុសិស្សអាចចេះពិចារណានិងមានការចងចាំច្រើន ។*

**ម៉ាត់ គះហៀវ**